**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦២ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការតាមដានត្រួតពិនិត្យ
## ការអនុវត្តកម្មវិធីកន្សោមអាទិភាព

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ

- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព ស្ថិតនៅក្រោមការដឹកនាំ និងការវាយតម្លៃផ្ទាល់ពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីតាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តកម្មវិធីកន្សោមអាទិភាពរបស់ក្រសួង ស្ថាប័ន ឱ្យមានប្រសិទ្ធភាព និងតម្លាភាព ព្រមទាំងធានាប្រក្រតីភាពការងាររបស់ក្រសួង ស្ថាប័ននីមួយៗ ។

**ប្រការ ២.-**

គណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១-តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-តំណាង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | អនុប្រធាន |
| ៣-តំណាង ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | សមាជិកអចិន្ត្រៃយ៍ |
| ៤- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- តំណាង ក្រសួង ស្ថាប័នសាមី | សមាជិក ។ |

ការតែងតាំងប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មការតាមដានត្រួតពិនិត្យ ការអនុវត្តកម្មវិធីកន្សោមអាទិភាព ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

**ប្រការ ៣.-**

សមាជិកគណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព ដែលមិនបានទទួលប្រាក់បំណាច់មុខងារតាមមាត្រា ១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និងតាមមាត្រា ៣ នៃអនុក្រឹត្យ លេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ ត្រូវបំពេញកិច្ចសន្យាការងារ និងត្រូវបានទទួលប្រាក់ឧបត្ថម្ភទៅតាមលក្ខខណ្ឌ ដូចសមាជិកកន្សោមអាទិភាព ។

ប្រការ ៤.-

គណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព មានភារកិច្ចចម្បងៗ ដូចតទៅ :

- សិក្សាស្វែងយល់អំពីបេសកកម្មអាទិភាព ព្រមទាំងឯកសារភ្ជាប់នានារបស់ក្រសួង ស្ថាប័ននីមួយៗ
- ពិនិត្យឯកសារស្តីពីភាពជឿនលឿននៃការអនុវត្តកម្មវិធីកន្សោមអាទិភាព និងការវាយតម្លៃការផ្តល់ប្រាក់ឧបត្ថម្ភជាក់ស្តែងជូនសមាជិកកន្សោមអាទិភាព
- រៀបចំការប្រជុំជាទៀងទាត់ ឬ វិសាមញ្ញតាមការចាំបាច់ ដើម្បីពិនិត្យភាពជឿនលឿននៃការងារ
- ធ្វើកំណត់ហេតុ ឬរបាយការណ៍ស្តីពីភាពជឿនលឿននៃការអនុវត្តកម្មវិធីកន្សោមអាទិភាពរបស់ក្រសួង ស្ថាប័ននីមួយៗ និងលើកយោបល់ជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីពិនិត្យ និង សម្រេច
- រៀបចំការប្រជុំដើម្បីដោះស្រាយការតវ៉ារបស់សមាជិកកន្សោមអាទិភាព
- បំពេញភារកិច្ចផ្សេងៗទៀត ដែលក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលប្រគល់ឱ្យ ដើម្បីធានាឱ្យដំណើរការនៃការអនុវត្តកម្មវិធីកន្សោមអាទិភាព ប្រព្រឹត្តទៅបានល្អប្រសើរ ។

ប្រការ ៥.-

សមាជិកគណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន ។

ប្រធានគណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព អាចអញ្ជើញតំណាងគណៈកម្មការជ្រើសរើសសមាជិកកន្សោមអាទិភាព និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឱ្យចូលរួមសង្កេតការណ៍រាល់ការប្រជុំវាយតម្លៃ និងសម្រេចការងារសំខាន់ៗ ។

ប្រការ ៦.-

សមាជិកគណៈកម្មការ ដែលអវត្តមានមិនបានចូលរួមប្រជុំចំនួន ៣ (បី) ដងជាប់ៗគ្នា ឬ ២/៣ (ពីរភាគបី) នៃការប្រជុំប្រចាំត្រីមាសដោយគ្មានមូលហេតុ ឬដោយត្រូវបានប្រធានស្ថាប័នចាត់តាំងឱ្យទទួលភារកិច្ចថ្មី ត្រូវផ្លាស់ប្តូរជំនួសវិញដោយសមាជិកមកពីក្រសួង ស្ថាប័នដូចគ្នា ។

ការតែងតាំងសមាសភាពដែលត្រូវផ្លាស់ប្តូរ ត្រូវធ្វើដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

ប្រការ ៧.-

គណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព ត្រូវអនុវត្តការងាររបស់ខ្លួនដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានតម្លាភាព ស្របតាមចក្ខុវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានភារកិច្ចជួយសម្រួលរាល់សេវាលេខាធិការ ក្នុងការអនុវត្តការងារ និងការរៀបចំកិច្ចប្រជុំផ្សេងៗ ដល់គណៈកម្មការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកន្សោមអាទិភាព ។

/...

ប្រការ ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

សុខ អាន

<u>**កន្លែងទទួល**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ដូចប្រការ ២
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ-កាលប្បវត្តិ